## បណ្ណកម្មសិទ្ធិដីផ្តល់ជូនប្រជាពលរដ្ឋនូវចំណែកមួយនៅក្នុងប្រទេសរបស់ខ្លួន

*"ពេលនេះ ខ្ញុំមានទំនុកចិត្តលើអនាគតរបស់ខ្ញុំ និងលើកូនខ្ញុំ ។ ពុំមានអ្នកណាអាចមកដណ្តើមដីខ្ញុំបានទេ ។ ដីនេះគឺពិតជាទ្រព្យរបស់ខ្ញុំមែន ។"*

--លោកយាយ ឱត សារី អាយុ ៦៦ ឆ្នាំ នៅពេលទទួលបានប័ណ្ណកម្មសិទ្ធិដីរបស់គាត់ ។

**ភូមិព្រៃស្ពឺ ជាយក្រុងភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៧** - "ខ្ញុំ ព្រឺសម្បុរណ៍គឺង្គក់ នៅពេលដែលអ្នកប្រកាសហៅឱ្យខ្ញុំឡើង ទៅ ទទួលប័ណ្ណកម្មសិទ្ធិដី" លោកយាយ ឱត សារី អាយុ ៦៦ ឆ្នាំ និយាយជាមួយនឹងដៃទាំងទ្វេររបស់គាត់កាន់ប័ណ្ណកម្មសិទ្ធិដ៏មានតម្លៃខណៈដែលឈរនៅជួរខាងមុខដើម្បីអរគុណគណៈប្រតិភូ ។ "ពេលនេះ ខ្ញុំមានទំនុកចិត្តលើអនាគតរបស់ខ្ញុំ និងសំរាប់កូនខ្ញុំ ។ ពុំមានអ្នកណាអាចមកដណ្តើមដីខ្ញុំបានទេ ។ ដីនេះគឺពិតជាទ្រព្យរបស់ខ្ញុំពិតៗ ។"



***លោក យាយ ឱត សារី ខាងឆ្វេង និង លោក ផាន់ ម៉ែន ខាងស្តាំ កំពុងបង្ហាញប័ណ្ណកម្មសិទ្ធិដីធ្លីថ្មី***

ជាមួយនឹងប័ណ្ណកម្មសិទ្ធិថ្មីរបស់គាត់នេះ លោកយាយមានផែនការប្រើប្រាស់វាយ៉ាងមានប្រសិទ្ធភាពៈ វានឹងជាភ័ស្តុតាងជាក់ស្តែង ដែលនឹងផ្តល់ឱ្យលោកយាយនូវលទ្ធភាពរកទុនដើម្បីធ្វើអាជីវកម្ម ឬសម្រាប់គ្រាអាសន្ន ។ លោកយាយជឿជាក់ថានៅពេលដែលគាត់ស្លាប់ទៅប័ណ្ណកម្មសិទ្ធិនេះនឹងរក្សាដីនោះទុកឱ្យកូនរបស់គាត់ ។

លោកពូ ផាន់ ម៉ែន អាយុ ៥៦ ឆ្នាំ ដែលជាកសិករមួយរូបទៀតដែលបានទទួលប័ណ្ណកម្មសិទ្ធិដី មានអារម្មណ៍ដូចគ្នានឹងលោកយាយ ឱត សារី ដែរ លោកមានប្រសាសន៍ថា "ចាប់ពីពេលនេះទៅ ដីរបស់យើងគឺមានសុវត្ថិភាពហើយ ពុំមានជម្លោះអំពីព្រំដីទៀតទេ ។"

ដោយសារកំណើនប្រជាជននៅក្នុងភូមិ និងការឡើងថ្លៃដីដ៏ខ្លាំង លោកពូ ម៉ែន យល់ថាដីពុំមានសុវត្ថិភាពទៀតទេ ប្រសិនបើពុំ មានឯកសារស្របច្បាប់ដើម្បីការពារវា ។ "ខ្ញុំបាទរីករាយខ្លាំងណាស់ដោយសារពេលនេះពុំមានអ្នកណាម្នាក់អាចដណ្តើមយកដីខ្ញុំបានឡើយ" គាត់និយាយជាមួយនឹងភាពញញឹមប្រកប ដោយក្តីសង្ឃឹម ។

អ្នកចូលរួមម្នាក់ទៀតគឺលោកពូ ម៉ម ឆយ អាយុ ៥៩ ឆ្នាំ ដែលកំពុងកាន់ឯកសារនានាដើម្បីផ្ទៀងផ្ទាត់នឹងបញ្ជីលើក្តារខៀននៅក្នុងវត្តព្រៃស្ពឺ ដែលនៅទីនោះពិធីប្រគល់ប័ណ្ណកម្មសិទ្ធិដីត្រូវបានប្រារព្ធធ្វើឡើង និយាយថា "ខ្ញុំបាទមកទីនេះដើម្បីពិនិត្យមើលឈ្មោះរបស់ខ្ញុំដើម្បីធានាឱ្យបានច្បាស់ថាវាត្រឹមត្រូវ ហើយបើមានកំហុស យើងអាចជូនដំណឹងដល់អាជ្ញាធរចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងកែតំរូវវា ។"

លោកយាយសារី លោកពូម៉ែន និងលោកពូ ឆយ គឺក្នុងចំណោមអ្នកភូមិចំនួន ៥00 នាក់ដែលបានទទួលប័ណ្ណកម្មសិទ្ធិនៅវត្តព្រៃស្ពឺ ខ័ណ្ឌដង្កោ ដែលមានទីតាំងនៅជាយក្រុងភ្នំពេញ ដែលនៅទីនោះ ប្រធានធនាគារពិភពលោក លោក រ៉ូបឺត ហ្សេអេលិក (Robert Zoellick) បានជួយក្នុងការចែកប័ណ្ណកម្មសិទ្ធិថ្មីជូនដល់អ្នកភូមិព្រៃស្ពឺ ។

លោក ហ្សេអេលិក មានប្រសាសន៍ថា *"ការរីកចំរើនលើការផ្ដល់ប័ណ្ណកម្មសិទ្ធិដី ធ្វើអោយប្រជាពលរដ្ឋកម្ពុជាដែលជាអ្នកក្រីក្រជាងគេ មានលទ្ធភាពអាចធ្វើជាម្ចាស់លើដីធ្លី ទាំងនៅក្នុងអនាគតរបស់ពួកគេ និងសំរាប់ប្រទេសរបស់ពួកគេ ។ ក៏ប៉ុន្តែប្រជាជនក្រីក្រ ជាច្រើននៅតែខ្វះខាតដីធ្លី ។ ជនមានអំណាចមួយចំនួន កំពុងព្យាយាមគ្រប់គ្រងផ្ទៃដីដែលមានទំហំធំ"* ។ លោកបន្តថា *"យើងចង់ធ្វើការងារនេះដើម្បីបង្កើនល្បឿនលើការផ្ដល់កម្មសិទ្ធិដីធ្លីនេះ ហើយធានាថា កិច្ចប្រឹងប្រែងនានា កំពុងត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍ជនក្រីក្រជាងគេបំផុត និងជនទាំងឡាយណា ដែលអាចងាយរងគ្រោះដោយសារការរឹបអូសយកដីរបស់ពួកគេ ដូចជាជនជាតិភាគតិចជាដើម ។ ប្រទេសកម្ពុជា ក៏កំពុងតែប្រឈមមុខទៅនឹងភារកិច្ចដ៏ធំមួយ ក្នុងការទាមទារយកមកវិញនូវដីសំខាន់ៗ និងបោសសំអាតមីនរាប់លានគ្រាប់ដែលបានកប់នៅក្នុងដីក្នុងកំឡុងពេលសង្គ្រាមជាច្រើនទសវត្សរ៍ គឺគ្រាប់មីនដែលនៅតែសំលាប់ និងធ្វើអោយរបួសមនុស្សរហូតមកសព្វថ្ងៃនេះ"* ។

លោក បានបន្តទៀតថា ការទទួលបាននូវសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ក៏នឹងជួយធ្វើអោយប្រជាជន មានលទ្ធភាពផងដែរក្នុងការធ្វើវិនិយោគលើដីចំការ អាជីវកម្មតូចតាច និងផ្ទះសំបែងរបស់ពួកពួកគាត់ ដើម្បីកែលំអសន្តិសុខផ្នែកហិរញ្ញវត្ថុ និងជីវិតរស់នៅរបស់ពួកគាត់ ។ *"ការផ្ដល់កម្មសិទ្ធិដី គឺជាអាទិភាពទីមួយរបស់យុទ្ធសាស្ត្រប្រឆាំងភាពក្រីក្រ និងបង្កើនអត្ថប្រយោជន៍នៃសេដ្ឋកិច្ច ដែលកំពុងរីកលូតលាស់"* ។



***លោក ហ្សេអេលិក ប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់កសិករ***

ជាមួយ នឹងការជួយគាំទ្រពីគម្រោងគ្រប់គ្រងដីធ្លីនិងរដ្ឋបាល (LMAP) ដែលទទួលហិរញ្ញប្បទានពីធនាគារពិភពលោក រាជរដ្ឋាភិបាល ជាពិសេស ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ កំពុងចេញប័ណ្ណកម្មសិទ្ធិជាង ២0 000 ប័ណ្ណ ក្នុងមួយខែៗ ភាគច្រើននៅតាមតំបន់ជនបទ ជាមួយនឹងកម្មសិទ្ធិ ៨0 ភាគរយត្រូវ បានចុះបញ្ជីរួមគ្នាដោយភរិយានិងស្វាមី ឬដោយគ្រួសារដែលមានមេគ្រួសារជាស្ត្រី ។ គម្រោងគ្រប់គ្រងដីធ្លីនិងរដ្ឋបាល ត្រូវបានគ្រោងឡើងដើម្បីកែលម្អសុវត្ថភាពកម្មសិទ្ធិ និងដើម្បីជម្រុញអភិវឌ្ឍន៍ទីផ្សារដីប្រកបដោយយុតិធម៌ ។

*ដើម្បីព័ត៌មានបន្ថែមអំពីកម្មវិធីរបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា សូមមើលវិបសាយភាសាអង់គ្លេសៈ* *http://www.worldbank.org/kh*